**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

CAMBODIA
Kingdom of Wonder
feel the warmth

លេខ ៧០១ ទសក

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ" ក្នុងវិស័យទេសចរណ៍ លើកទី១ ឆ្នាំ២០១៧

### I. សេចក្តីផ្តើម

ដើម្បីចូលរួមចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"** រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវចលនាប្រឡងប្រណាំង **"បដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍"** សំដៅជម្រុញ និងលើកទឹកចិត្តដល់ប្រតិបត្តិករទេសចរណ៍ឱ្យខិតខំប្រឹងប្រែងអភិវឌ្ឍន៍សម្បទាទេសចរណ៍របស់ខ្លួនប្រកបដោយស្តង់ដាត្រឹមត្រូវ អភិរក្សវប្បធម៌ ប្រពៃណីរបស់ជនជាតិខ្មែរ លើកកំពស់ធនធានមនុស្សដែលមានជំនាញ គុណភាព ប្រសិទ្ធភាពខ្ពស់សំដៅទាក់ទាញទេសចរក៏ដូចជាពន្យារការស្នាក់នៅរបស់ទេសចរ និងចូលរួមបង្កើនដល់ការលើកកម្ពស់ កម្ពុជាជាគោលដៅទេសចរណ៍ប្រកបដោយភាពទាក់ទាញ និងផ្តល់ភាពកក់ក្តៅដល់ភ្ញៀវទេសចរ និងប្រកបដោយផាសុកភាពសម្រាប់ការស្នាក់នៅរបស់ភ្ញៀវទេសចរ សក្តិសមនឹងប្រសិទ្ធនាមៈ **"កម្ពុជាៈ ព្រះរាជាណាចក្រអច្ឆរិយៈ"** ផ្តល់ភាពកក់ក្តៅ។

### II. យន្តការនៃការប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ" ក្នុងវិស័យទេសចរណ៍

ចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ"ក្នុងវិស័យទេសចរណ៍ ធ្វើឡើងផ្អែកលើការវាយតម្លៃរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិលើសេវាបដិសណ្ឋារកិច្ចដែលផ្តល់ដោយប្រតិបត្តិករទេសចរណ៍។ ប្រតិបត្តិករទេសចរណ៍ដែលបំរើសេវាទេសចរណ៍ដូចជា សណ្ឋាគារ និងសេវាស្នាក់នៅ ភោជនីយដ្ឋាន ហាងលក់វត្ថុអនុស្សាវរីយទេសចរណ៍ មណ្ឌលកម្សាន្តមនុស្សពេញវ័យ ហាងស្ប៉ា និងម៉ាស្សា មគ្គុទ្ទេសក៏ទេសចរណ៍ និងទីភ្នាក់ងារទេសចរណ៍ដែលមានអាជ្ញាបណ្ណពីក្រសួងទេសចរណ៍ តម្រូវឱ្យដាក់ពាក្យចូលរួមប្រឡងប្រណាំង **"បដិសណ្ឋារកិច្ចល្អ" ក្នុងវិស័យទេសចរណ៍ ឆ្នាំ២០១៧** នេះជាកាតព្វកិច្ច។ ចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ"ក្នុងវិស័យទេសចរណ៍នេះ ត្រូវបានវាយតម្លៃដោយផ្អែកលើការពេញចិត្តរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិដែលទទួលសេវាផ្ទាល់ពីមូលដ្ឋានអាជីវកម្មទេសចរណ៍តែប៉ុណ្ណោះ។

### III. ដំណើរការនៃការប្រឡងប្រណាំង

ដំណើរការនៃការប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ"ក្នុងវិស័យទេសចរណ៍ធ្វើឡើងជា**រៀងរាល់ឆ្នាំ** ដោយចែកចេញជា **០៣ (បី)** ដំណាក់កាល ដូចខាងក្រោមៈ

- **ដំណាក់កាលទី១៖ ខែមិថុនា ឆ្នាំ២០១៧ ដល់ ខែកក្កដា ឆ្នាំ២០១៧** មូលដ្ឋានអាជីវកម្មទេសចរណ៍ត្រូវដាក់ពាក្យសុំចូលរួមប្រឡងប្រណាំងតាមរយៈគេហទំព័រ www.cambodiabesthospitality.org (អាចចូលបានតាមការស្កេនQR-Code) ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធចាំបាច់នានា។ មូលដ្ឋានអាជីវកម្មទេសចរណ៍ក៏អាចធ្វើការចុះឈ្មោះចូលរួមប្រឡងប្រណាំងដោយគ្រាន់តែបំពេញពាក្យសុំចូលរួមប្រឡងប្រណាំង និងផ្ញើមក អ៊ីម៉ែល info@cambodiabesthospitality.org ។
- **ដំណាក់កាលទី២៖ ខែសីហា ឆ្នាំ២០១៧ ដល់ ខែមករា ឆ្នាំ២០១៨** ភ្ញៀវទេសចរជាតិ និងអន្តរជាតិ និងប្រជាពលរដ្ឋអាចចូលរួមការវាយតម្លៃ (Vote) ដោយផ្ទាល់ ឬតាមប្រព័ន្ធវាយតម្លៃអនឡាញ (www.cambodiabesthospitality.org) ឬអាចចូលវាយតម្លៃដោយគ្រាន់តែស្កេន QR-Code របស់សេវាណាមួយ និងធ្វើការវាយតម្លៃ។
- **ដំណាក់កាលទី៣ ខែមិថុនា ឆ្នាំ២០១៨** ក្រសួងទេសចរណ៍ នឹងរៀបចំរបាយការណ៍ចុងក្រោយ និងឈានទៅប្រកាសលទ្ធផលជ័យលាភី **"បដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍"** លើកទី១។

ចំពោះព័ត៌មានលំអិតទាក់ទងនឹងចលនាប្រឡងប្រណាំង **"បដិសណ្ឋារកិច្ចល្អ" ក្នុងវិស័យទេសចរណ៍ លើកទី១** សូមទំនាក់ទំនងទូរស័ព្ទលេខ៖ (៨៥៥) ៧៨ ៧៧៧ ១៦៧, (៨៥៥) ៩៤៤ ៤៩៨

អ៊ីម៉ែល ៖ info@cambodiabesthospitality.org

ឬគេហទំព័រ ៖ www.cambodiabesthospitality.org

ក្រោយពីទទួលបានសេចក្តីជូនដំណឹងនេះ សូម **ឯកឧត្តម លោកជំទាវ លោក-លោកស្រី** ដែលជាម្ចាស់ ឬ អ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្តទាំងអស់ ជ្រាបជាព័ត៌មាន និងសូមចូលរួមក្នុងការប្រឡងប្រណាំងខាងលើនេះ ឱ្យបានផុសផុល។

**ក្រសួងទេសចរណ៍**